មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការស៊ើបអង្កេតត្រូវតែប្រកបដោយតម្លាភាព និងឯករាជ្យភាព

**ឆាំង យុ**

***ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

មជ្ឈមណ្ឌលឯកសារកម្ពុជាសូមសម្តែងនូវចំណាប់អារម្មណ៍ ចំពោះដំណើរការវិវឌ្ឍន៍ថ្មីៗស្តីអំពីការស៊ើបអង្កេតករណី០០៣ និង០០៤ នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដំណើរការដែលប្រកបទៅដោយឯករាជ្យភាព និងតម្លាភាពរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាកិច្ចការមិនអាចខ្វះបាន ប្រសិនបើប្រជាជនកម្ពុជានិងត្រូវទទួលបានភាពយុត្តិធម៌ចំពោះអំពើព្រៃផ្សៃដែលខ្លួនបានទទួលរងក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

កាលពីថ្ងៃទី២៩ ខែមេសា កន្លងទៅសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជាបានធ្វើការប្រកាសយ៉ាងប្រញាប់ប្រញាល់អំពីការបិទដំណើរការស៊ើបអង្កេតចំពោះករណី០០៣ ។ ការប្រកាសជាសាធារណនោះមិនបានរៀបរាប់អំពីបទឧក្រិដ្ឋដែលបានធ្វើការស៊ើបអង្កេតរួចមកហើយទេ ទោះបីជាជនរងគ្រោះដែលទទួលរងនូវការធ្វើទុក្ខបុកម្នេញ ដោយបុព្វហេតុនោះផ្ទាល់មានរយៈពេល១៥ថ្ងៃដើម្បីចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការក្តីនាថ្ងៃអនាគត ។ ការិយាល័យ កិច្ចការសាធារណៈមិនបានធ្វើការពន្យល់ដល់ប្រជាជនកម្ពុជាទូទៅអំពីអត្ថន័យនិងផលលំបាកនៃដំណើរការវិវឌ្ឍន៍នេះនៅឡើយទេ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាប្តូរផ្តាច់និងបម្រើគោលដៅទាំងពីរ របស់ខ្លួនគឺការចងចាំនិងយុត្តិធម៌ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាឃ្លាំងស្តុកឯកសារទាក់ទងនិងរបបខ្មែរក្រហមដ៏ធំបំផុតនៅលើពិភពលោក មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជំនួយនិងការគាំទ្រ ដល់ដំណើរការស្វែងរកការទទួលខុសត្រូវរបស់សាលាក្តីខ្មែរក្រហមតាំងពីស្ថាប័ននេះចាប់ដំណើរការដំបូងមកម្ល៉េះ ។ ប្រជាជនកម្ពុជាដែលរួចរស់ជីវិតពីរបបខ្មែរក្រហមរាប់លាននាក់សមនឹងទទួលបានព័ត៌មានថា តើសាលាក្តីខ្មែរក្រហមកំពុងធ្វើអ្វីដើម្បីបម្រើផលប្រយោជន៍ខ្លួនដែលជាជនរងគ្រោះ ប៉ុន្តែសាលាក្តីខ្មែរក្រហមមិនបានផ្តល់ព័ត៌មានដ៏មានអត្ថន័យណាមួយដល់សាធារណជន អំពីករណី០០៣និង០០៤ទេ ចាប់តាំងពីសហចៅក្រមស៊ើបអង្កេតចាប់ផ្តើមដំណើរការស៊ើបអង្កេតរបស់ខ្លួនតាំងពី២០ខែកន្លងមកហើយយ៉ាងណាក្តី ។

ក្នុងនាមជាស្ថាប័នដែលមានជំនឿលើភាពស្របច្បាប់របស់ដំណើរការសាលាក្តីខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាគោរព នូវភាពលាក់ការណ៍នៃដំណើរការស៊ើបអង្កេតរបស់តុលាការ ។ ជាមួយគ្នានោះដែរ យើងនៅតែចង់ដឹងហេតុការណ៍ប្រវត្តិសាស្ត្រពិត ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលប្រព្រឹត្តិឡើងដោយរបបខ្មែរក្រហមរួមទាំងអ្នកដែលនឹងត្រូវស៊ើបអង្កេតសម្រាប់ករណី០០៣ និង០០៤ ព្រមទាំងដើម្បីប្រមូលឯកសារដែលនឹងអាចប្រើប្រាស់បាននៅក្នុងដំណើរការច្បាប់នេះផង ។

យើងរំពឹងថា សាលាក្តីខ្មែរក្រហមនឹងមានជំហរប្រកបទៅដោយបទដ្ឋានខ្ពស់បំផុតនៃឯករាជ្យភាពខាងផ្លូវច្បាប់របស់ខ្លួន ។ រាល់សេចក្តីសម្រេចទាំងអស់របស់សាលាក្តីខ្មែរក្រហមត្រូវតែធ្វើឡើងដោយឯករាជ្យពីសម្ពាធនយោបាយ និងអនុលោមតាមការបកស្រាយដ៏ច្បាស់លាស់របស់វិធានតុលាការ ។ លើសពីនេះទៅទៀត យើងសូមស្នើថា តុលាការជម្រាបដំណឹងដល់ប្រជាជនកម្ពុជាឲ្យបានគ្រប់គ្រាន់អំពីដំណើរកិច្ចការងាររបស់ខ្លួន ។

**- ចប់ -**